**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការ និងដឹកជញ្ជូន**

លេខ:១១៣ ប្រក...........សកដក

**លិខិតចូល**

ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៩

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ 2009

# ប្រកាស

## ស្តីពី

## ការប្រឡងយកវិញ្ញាបនប័ត្របញ្ជាក់សមត្ថភាព របស់គ្រូបង្ហាត់បើកបរយានយន្ត និងគណៈកម្មការប្រឡងយកប័ណ្ណបើកបរ នៅរាជធានី ខេត្ត

## រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត ០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស / រកម ០១៩៦/ ០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសាធារណការ និង ដឹកជញ្ជូន

-បានឃើញព្រះរាជក្រម លេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោក

-បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ. បក ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារការ និង ដឹកជញ្ជូន

-យោងតាមការចាំបាច់របស់ក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**ប្រការ ១ :** គ្រូបង្ហាត់បើកបរយានយន្ត ទាំងពីរភេទដែលកំពុងបង្ហាត់ ឬដែលមានបំណងធ្វើជាគ្រូបង្ហាត់នៅសាលាបង្រៀនបើកបរ ឬមន្ត្រីរាជការទាំងពីរភេទ ដែលជាគណៈកម្មការប្រឡងយកប័ណ្ណបើកបរ ឬមានបំណងធ្វើជាសមាជិកគណៈកម្មការប្រឡងយកប័ណ្ណបើកបរយានយន្ត ត្រូវមានវិញ្ញាបនប័ត្របញ្ជាក់សមត្ថភាព ចេញដោយរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន តាមរយៈការប្រឡងដែលចាត់ចែងដោយ អគ្គនាយកដ្ឋានដឹកជញ្ជូន នៃក្រសួងសាធារណការ និងដឹកជញ្ជូន ។

**ប្រការ ២ :** បុគ្គលទាំងពីរភេទដែលមានចែងក្នុងប្រការ ១ ត្រូវបំពេញនូវល័ក្ខខ័ណ្ឌ ដូចខាងក្រោម :

១-ត្រូវមានសញ្ជាតិខ្មែរ និងមានអាយុយ៉ាងតិច ២៥ឆ្នាំឡើងទៅ ។

២-ត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ ឬសញ្ញាប័ត្រដែលមានតំលៃប្រហាក់ប្រហែល ឬលើសពីនេះ ។

៣-មានកាយសម្បទាគ្រប់គ្រាន់ ដែលមានការបញ្ជាក់សុខភាពពីវេជ្ជបណ្ឌិត ។

៤-ត្រូវមានប័ណ្ណបើកបរ និងបទពិសោធន៍ក្នុងការបើកបរយ៉ាងតិច ៣ឆ្នាំ តាមប្រភេទប័ណ្ណបើកបរដែលតំរូវការក្នុងការប្រឡងយកវិញ្ញាបនប័ត្របញ្ជាក់សមត្ថភាពរបស់គ្រូបង្ហាត់បើកបរយានយន្ត។

**ប្រការ ៣ :** បែបបទ នៃការដាក់ពាក្យសុំប្រឡង មានដូចខាងក្រោម:

| | |
|---|---|
| ១- ពាក្យសុំប្រឡងដែលមានបិទតែមប្រិយ៍ | ចំនួន ១ ច្បាប់ |
| ២- អត្តសញ្ញាណប័ណ្ណ ឬប័ណ្ណគ្រួសារ ឬលិខិតបញ្ជាក់ពីរដ្ឋអំណាច( ថតចម្លង) | ចំនួន ១ សន្លឹក |
| ៣- រូបថតថ្មីទំហំ ៤ x ៦ ( ថតចំពីមុខក្នុងរយៈពេល ៦ខែ ) | ចំនួន ៤ សន្លឹក |
| ៤- លិខិតពិនិត្យសុខភាព ពីមន្ទីរពេទ្យរដ្ឋ ដោយមានបិទរូបថត ៤ x៦ | ចំនួន ១ សន្លឹក |
| ៥- សញ្ញាប័ត្រ មធ្យមសិក្សាបឋមភូមិ ឬសញ្ញាប័ត្រដែលមានតម្លៃប្រហាក់ប្រហែល | ចំនួន ១ សន្លឹក |
| ៦- ប័ណ្ណបើកបរទោចក្រយានយន្ត ឬ រថយន្ត ថតចម្លង ) | ចំនួន ១ សន្លឹក |
| ៧- ឯកសារផ្សេងៗដែលចាំបាច់ | |

ចំពោះថ្លៃសេវាប្រឡងត្រូវអនុវត្តតាមប្រកាសអន្តរក្រសួងរវាង ក្រសួងសាធារណការ និងដឹកជញ្ជូន និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ ៤ :** ល័ក្ខខ័ណ្ឌ នៃប្រភេទប័ណ្ណបើកបរសម្រាប់ប្រឡងយកវិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្ត ត្រូវកំណត់ដូចខាងក្រោម :

១- បេក្ខជនដែលមានប័ណ្ណបើកបរប្រភេទ **ក២** សម្រាប់ប្រឡងយកវិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្តប្រភេទ**ក**

២- បេក្ខជនដែលមានប័ណ្ណបើកបរប្រភេទ **ខ គ ឃ** ឬ **ង** សម្រាប់ប្រឡងយកវិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្តប្រភេទ**ខ** ។

៣- បេក្ខជនដែលមានប័ណ្ណបើកបរប្រភេទ គ **ឃ២ ង**(គ) ឬ **ង** (**ឃ២**) សម្រាប់ប្រឡងយកវិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្តប្រភេទ**គ** ។

៤- បេក្ខជនដែលមានប័ណ្ណបើកបរប្រភេទ **ឃ២** ឬ **ង** (**ឃ២**) សម្រាប់ប្រឡងយកវិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្តប្រភេទ **ឃ** ។

៥- បេក្ខជនដែលមានប័ណ្ណបើកបរប្រភេទ ង (គ) ឬ **ង**(**ឃ២**)សម្រាប់ប្រឡងយកវិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្តប្រភេទ **ង** ។

**ប្រការ ៥ :** ល័ក្ខខ័ណ្ឌ នៃការប្រឡងយកវិញ្ញាបនប័ត្របញ្ជាក់សមត្ថភាព មានដូចខាងក្រោម :

១- បេក្ខជនត្រូវទទួលការដាក់ពាក្យសុំចុះឈ្មោះប្រឡងនៅអគ្គនាយកដ្ឋានដឹកជញ្ជូន ។

២- បេក្ខជនត្រូវបានទទួលការបំពាក់បំប៉នរយៈពេល ១៥ទៅ៣០ថ្ងៃ មុនពេលប្រឡងនៅ អគ្គនាយកដ្ឋានដឹកជញ្ជូន តាមកម្មវិធីដែលកំណត់ដោយ អគ្គនាយកដ្ឋានដឹកជញ្ជូន ។

៣- បេក្ខជនត្រូវធ្វើការប្រឡងទ្រឹស្តី និង អនុវត្តបើកបរយានយន្តទៅតាមវិញ្ញាសារដែលកំណត់ដោយអគ្គនាយកដ្ឋានដឹកជញ្ជូន ។

៤- បេក្ខជនត្រូវធ្វើការប្រឡងទ្រឹស្តីដោយត្រូវគូស (☑) នៅក្នុងប្រអប់លើក្រដាសវិញ្ញាសារប្រឡងដែលមានសំណួរ និង ចម្លើយស្រាប់ ។

៥- បេក្ខជនប្រឡងផ្នែកទ្រឹស្តីជាប់ ទើបមានសិទ្ធិប្រឡងផ្នែកអនុវត្តបើកបរ ។

៦- បេក្ខជនត្រូវធ្វើការប្រឡងអនុវត្តបើកបរ នៅទីលានប្រឡងបើកបរយានយន្ត និងនៅលើផ្លូវសាធារណៈ ។

៧- ក្នុងករណីប្រឡងធ្លាក់ផ្នែកទ្រឹស្តី លើកទី១ បេក្ខជនត្រូវដាក់ពាក្យសុំប្រឡងទ្រឹស្តីជា លើកទី២ ។ ក្នុងករណីប្រឡងធ្លាក់ជាលើកទី២ បេក្ខជនត្រូវចុះឈ្មោះប្រឡងនៅពេលក្រោយសារជាថ្មី បើសិនជាតម្រូវការឱ្យមានជ្រើសរើសបន្ថែមទៀត ។

៨- បេក្ខជនប្រឡងទ្រឹស្តីជាប់ប៉ុន្តែ ប្រឡងផ្នែកអនុវត្តបើកបរធ្លាក់ ត្រូវប្រឡងតែផ្នែកអនុវត្តបើកបរជាលើកទី ២ឡើងវិញប៉ុណ្ណោះ ក្នុងករណីប្រឡងអនុវត្តបើកបរធ្លាក់លើកទី ២បេក្ខជន ត្រូវដាក់ពាក្យសុំចុះឈ្មោះប្រឡងនៅពេលក្រោយសារជាថ្មី បើសិនជាតម្រូវការឱ្យមានការជ្រើសរើសបន្ថែមទៀត ។

**ប្រការ ៦ :** គ្រប់វិញ្ញាបនប័ត្របញ្ជាក់សមត្ថភាពរបស់គ្រូបង្ហាត់បើកបរយានយន្ត ត្រូវចេញដោយ ក្រសួងសាធារណការ និងដឹកជញ្ជូន តាមការស្នើសុំរបស់អគ្គនាយកដ្ឋានដឹកជញ្ជូន ។

**ប្រការ ៧ :** វិញ្ញាបនប័ត្របញ្ជាក់សមត្ថភាព របស់គ្រូបង្ហាត់បើកបរយានយន្ត អាចបង្ហាត់ទាំងទ្រឹស្តី និងអនុវត្តបើកបរ ទៅតាមប្រភេទប័ណ្ណបើកបរនីមួយៗ ដូចខាងក្រោម :

១- វិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្តប្រភេទ **ក** អាចបង្ហាត់បើកបរទេ ចក្រយានយន្ត និងត្រីចក្រយានយន្ត ប្រភេទ **ក១** និង **ក២** ។

២- វិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្តប្រភេទ **ខ** អាចបង្ហាត់បើកបររថយន្តធុនតូច ប្រភេទ **ខ**

៣- វិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្តប្រភេទ **គ** អាចបង្ហាត់បើកបររថយន្តធុនតូច ប្រភេទ **ខ** និង រថយន្តដឹកទំនិញធុនធំប្រភេទ **គ** ។

៤- វិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្តប្រភេទ **ឃ** អាចបង្ហាត់បើកបររថយន្តធុនតូចប្រភេទ **ខ** រថយន្តដឹកទំនិញធុនធំប្រភេទ **គ** រថយន្តដឹកអ្នកដំណើរធុនមធ្យមប្រភេទ **ឃ១** និង រថយន្តដឹកអ្នកដំណើរធុនធំប្រភេទ **ឃ២** ។

៥- វិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្តប្រភេទ **ង** អាចបង្ហាត់បើកបររថយន្តធុនតូចប្រភេទ **ខ** រថយន្តដឹកទំនិញធុនធំប្រភេទ **គ** និងរថយន្តសណ្តោងរ៉ឺម៉ក ប្រភេទ **ង(ខ)** **ង(គ)** **ង(ឃ១)** និង **ង(ឃ២)** ។

**ប្រការ ៨ :** វិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្ត មានសុពលភាពប្រើប្រាស់រយៈពេល ៣ឆ្នាំ ។ ក្នុងករណីសាមីខ្លួនចង់បន្តនូវអាជីពជាគ្រូបង្ហាត់បើកបរយានយន្តបន្តទៀត ត្រូវមកសុំពន្យារពេលប្រើប្រាស់ក្នុងរយៈពេល ៣ឆ្នាំម្តង១ ដោយត្រូវឆ្លងកាត់ការអប់រំបំពាក់បំប៉នបន្ថែមរយៈពេលពី មួយថ្ងៃទៅ បីថ្ងៃ ។ វិញ្ញាបនប័ត្រ

គ្រូបង្ហាត់បើកបរយានយន្ត ត្រូវយកមកធ្វើការពន្យារ ឬប្តូរក្នុងរយៈពេល ៣០ថ្ងៃមុនពេលអស់សុពលភាពប្រើប្រាស់ ។

**ប្រការ ៩ :** ការដកហូត ព្យួរទុក ឬ ទុកជាមោឃៈនូវវិញ្ញាបនប័ត្រគ្រូបង្ហាត់បើកបរយានយន្ត ក្នុងករណីដូចខាងក្រោម :

១- អស់សុពលភាពប្រើប្រាស់ ដែលបានកំណត់ក្នុងវិញ្ញាបនប័ត្រ ។

២- គ្រូបង្ហាត់បើកបរយានយន្តដែល ពុំបានអនុវត្តនីត្រឹមត្រូវតាមល័ក្ខខ័ណ្ឌទាំងឡាយនៃការបង្ហាត់បើកបរយានយន្តគ្រប់ប្រភេទ ។

៣- នៅតែមានគុណធម៌ចរិយាធម៌មិនត្រឹមត្រូវ ក្រោយពីបានទទួលការអប់រំណែនាំជាលាយល័ក្ខអក្សរ ចំនួន ៣ដង រួចហើយ ។

៤- មានសតិបញ្ញា ស្មារតី និងសុខភាពមិនប្រក្រតី ។

**ប្រការ ១០ :** នាយកសាលាបង្រៀនបើកបរយានយន្តណាមួយដែលប្រព្រឹត្តល្មើសនឹងបទបញ្ញត្តិនេះត្រូវទទួលការពិន័យដូចខាងក្រោម :

- ព្រមានជាលាយលក្ខអក្សរ
- ករណីមិនរាងចាលត្រូវដកហូតលិខិតអនុញ្ញាតធ្វើអាជីវកម្ម
- ក្នុងករណីប្រព្រឹត្តល្មើសធ្ងន់ធ្ងរ ត្រូវបញ្ជូនសំណុំលិខិតទៅស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ ១១ :** គ្រប់មន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី ខេត្ត ត្រូវតែងតាំងតែមន្ត្រីរាជការណាដែលមានវិញ្ញាបនប័ត្របញ្ជាក់សមត្ថភាពឱ្យធ្វើជាគណៈកម្មការប្រឡងយកប័ណ្ណបើកបរយានយន្ត ។

**ប្រការ ១២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១៣ :** នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាល អគ្គនាយកដឹកជញ្ជូន នាយកមន្ទីរសាធារណការ និងដឹកជញ្ជូន រាជធានី ខេត្ត នាយកសាលាបង្រៀនបើកបរយានយន្តត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ. ។

ត្រាំ អ៊ីវទឹក

ចម្លងជូន :
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-សាលា រាជធានី ខេត្ត
"ដើម្បីជូនជ្រាប"
-រាជកិច្ច
-ដូចប្រការ ១៣ "ដើម្បីអនុវត្តន៍"
-ឯកសារ កាលប្បវត្តិ